តើអ្នកគិតពីអ្វី ?

ឪពុកម្ដាយខ្ញុំមិនបានផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធទេ ។ តើមានន័យថាខ្ញុំមិនអាចមានចំណែកក្នុងគ្រួសារដ៏អស់កល្បទៅមែនទេ ?
—រុនឌើង មកពីរាជធានីវ៉ាសេរ

## ជូនចំពោះ រុនឌើង

អ្នកគឺជាបុត្រម្នាក់របស់ព្រះមាតាបិតាសួគ៌ ។ សូម្បីតែមុនពេលអ្នកមកកាន់ផែនដីនេះក៏ដោយ អ្នកជាផ្នែកនៃគ្រួសាររបស់ទ្រង់ទាំងទ្វេ ។ ហើយការណ៍នោះនឹងមិនផ្លាស់ប្ដូរឡើយ ! ដូច្នេះទោះបីជាយ៉ាងណាក៏ដោយ អ្នកនឹងនៅតែមានចំណែកក្នុងគ្រួសារដ៏អស់កល្បជានិច្ចដដែល !

ព្រះវរបិតាសួគ៌ស្រឡាញ់អ្នក រួមទាំងឪពុកម្ដាយអ្នកយ៉ាងខ្លាំង ។ ទ្រង់សព្វព្រះទ័យឲ្យអ្នកទាំងអស់គ្នាត្រឡប់ទៅរកទ្រង់វិញ ។ ទ្រង់នឹងបន្តប្រទានពរ ហើយដឹកនាំអ្នក និងគ្រួសាររបស់អ្នក ។ សូមអធិស្ឋានទៅកាន់ទ្រង់ពីរឿងដែលអ្នកព្រួយបារម្ភ ហើយទ្រង់នឹងលួងលោមអ្នក ។

ដោយក្ដីស្រឡាញ់

ទស្សនាវដ្ដី *ប្រិយមិត្ត*

សូមគូររូបសមាជិកម្នាក់ៗនៅក្នុងគ្រួសាររបស់អ្នក រួមទាំងអ្វីដែលអ្នកៗស្រឡាញ់អំពីពួកគាត់ ! សូមរកមើលចំណុចល្អនៅក្នុងគ្រួសាររបស់អ្នក ។ សូមប្រាប់ពួកគាត់ពីអ្វីដែលអ្នកយល់ឃើញ !

គ្រួសារខ្ញុំ និងខ្ញុំ

គ្រួសាររបស់អ្នក គឺលើសពីអ្នក និងឪពុកម្ដាយរបស់អ្នកៗទៅទៀត ។ គ្រួសាររបស់អ្នកមាន ជីដូនជីតារបស់អ្នក បងអ្នកជីដូនមួយ រួមទាំងបុព្វការីជនរបស់អ្នកផងដែរ ។ នៅថ្ងៃណាមួយគ្រួសាររបស់អ្នកអាចរាប់បញ្ចូលស្វាមី ឬ ភរិយារបស់អ្នកៗ រួមទាំងកូនចៅរបស់អ្នកផងដែរ ។ ហើយនោះជាគ្រួសារដ៏ធំមួយ !